សាកលវិទ្យាល័យន័រតុន

NORTON UNIVERSITY

# បទបញ្ញាផ្ទៃក្នុង

# Internal Regulation



ន័រតុនៈ មាគ៌ាសម្រាប់យើងគ្រប់គ្នាឆ្លងកាត់អន្តរជាតូបនីយកម្មនៃការសិក្សា និងជំនាញ !

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីសម្រេច
# ស្តីពី
# បទបញ្ជាផ្ទៃក្នុង
# សម្រាប់និស្សិត
# សាកលវិទ្យាល័យន័រតុន

## *សាកលវិទ្យាធិការ*

- *បានឃើញអនុក្រឹត្យលេខ៥១អនក្រ, បក ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពី ការបង្កើតមហាវិទ្យាល័យន័រតុន ដែលគ្រប់គ្រងដោយលោក ចាន់ សុខឃាង*
- *បានឃើញអនុក្រឹត្យលេខ៤៦អនក្រ, បក ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០២ ស្តីពី ការកែប្រែរចនាសម្ព័ន្ធនៃមហាវិទ្យាល័យន័រតុន ទៅជាសាកលវិទ្យាល័យន័រតុន*
- *បានឃើញបទបញ្ជាផ្ទៃក្នុង សម្រាប់និស្សិតថ្នាក់បរិញ្ញាបត្រ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៣*
- *តាមការចាំបាច់របស់សាកលវិទ្យាល័យន័រតុន*

# សម្រេច
## ជំពូកទី ១
## លក្ខខណ្ឌនៃការចូលរៀន

**ប្រការ ១.** លក្ខខណ្ឌទទួលសិស្សឲ្យចូលរៀន៖

**ក.** អាចចូលរៀនឆ្នាំទី១ (ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន) ថ្នាក់បរិញ្ញាបត្របាន បេក្ខជនទាំងពីរភេទជា សិស្ស និស្សិត ប្រជាពលរដ្ឋ ព្រះសង្ឃ និងមន្ត្រីរាជការ ត្រូវមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (Bac II) ឬ សញ្ញាបត្រ ដែលមានតម្លៃស្មើ។

**ខ.** សម្រាប់ថ្នាក់ក្រោយឧត្តមសិក្សា និស្សិតត្រូវមាន សញ្ញាបត្របរិញ្ញាបត្រ ឬ សមមូលនឹងបរិញ្ញាបត្រ។

**គ.** និស្សិតដែលមានសញ្ញាបត្រ ឬ វិញ្ញាបនបត្របញ្ជាក់ការសិក្សានៅគ្រឹះស្ថានឧត្តមសិក្សានានា អាចចូលរៀននៅសាកលវិទ្យាល័យន័រតុនបាន លុះត្រាតែបានឆ្លងកាត់ការវាយតម្លៃរបស់គណៈកម្មការនៃសាកលវិទ្យាល័យ។

**ប្រការ ២.** និស្សិតគ្រប់រូបត្រូវបង់ប្រាក់ថ្លៃសិក្សាជាមុន រៀងរាល់ដើមឆ្នាំសិក្សានីមួយៗ។ ប្រាក់នេះ មិនអាចដកវិញបានទេ (មុន និងក្រោយពេលបវេសនកាល)។

# ជំពូកទី ២
# អំពីវិន័យ
## ផ្នែកទី ១
## ឯកសណ្ឋាន

**ប្រការ ៣.** និស្សិតទាំងពីរភេទ លើកលែងតែនិស្សិតពេលយប់ ត្រូវស្លៀកពាក់ឯកសណ្ឋានដែលកំណត់ដោយសាកលវិទ្យាល័យ។

**ក.** និស្សិតប្រុស: ស្លៀកខោជើងវែងពណ៌ខៀវក្រមៅ និងអាវពណ៌ផ្ទៃមេឃ។ ត្រូវដាក់អាវក្នុងខោ ពាក់ស្បែកជើងឃ្លុប ឬ ស្បែកជើងស៊ក។

**ខ.** និស្សិតស្រី: ស្លៀកសំពត់ពណ៌ខៀវក្រមៅ ចាប់ពីក្រោមជង្គង់ចុះក្រោម និងអាវពណ៌ផ្ទៃមេឃ ដាក់អាវក្នុងសំពត់ ពាក់ស្បែកជើងឃ្លុប ឬ ក្រវាត់កែង។

**គ.** និស្សិតពេលយប់ ត្រូវស្លៀកពាក់សមរម្យ និងថ្លៃថ្នូរ។
- ត្រូវដាក់អាវក្នុងខោ ឬ ក្នុងសំពត់ (លើកលែងអាវមានហោប៉ៅបី ឬ ខោអាវឈុត)
- ហាមពាក់អាវយឺតវាល-ក ឬ ក៏អាវកម្ពល
- ហាមស្លៀកខោជើងខ្លី

**ឃ.** និស្សិតទាំងពីរភេទ ព្រឹក រសៀល និងយប់ ហាមពាក់ស្បែកជើងផ្ទាត់ (ចំពាម) ចូលក្នុងបរិវេណ ឬ ថ្នាក់រៀននៃសាកលវិទ្យាល័យ។

**ប្រការ ៤.** នៅពេលប្រឡង និងការពារសារណា ឬ ចូលរួមក្នុងពិធីផ្សេងៗ របស់សាកលវិទ្យាល័យ និស្សិតទាំងពីរភេទ ត្រូវស្លៀកពាក់ឯកសណ្ឋានដូចកំណត់ក្នុងប្រការ ៣ ខាងលើ ព្រមទាំងពាក់ក្រវាត់កពណ៌ខៀវ

មាននិមិត្តសញ្ញាសាកលវិទ្យាល័យន័រតុន។

**ប្រការ ៥.** និស្សិតពេលព្រឹក រសៀល និងយប់ ត្រូវពាក់ប័ណ្ណសម្គាល់ខ្លួនរាល់ពេលចេញចូលនៅក្នុងបរិវេណ និងក្នុងថ្នាក់រៀននៃសាកលវិទ្យាល័យ។

## ផ្នែកទី ២
## អំពីការសិក្សា

**ប្រការ ៦.** និស្សិតត្រូវអនុវត្តតាមកាលវិភាគ និងកម្មវិធីសិក្សាដែលបានកំណត់ដោយសាកលវិទ្យាល័យ។

**ប្រការ ៧.** ក្រោយពីបញ្ចប់ឆ្នាំទីមួយ (ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន) និស្សិតអាចដាក់ពាក្យសុំចូលរៀនបន្តឆ្នាំទី២ ផ្នែកណាមួយតាមឧបនិស្ស័យផ្ទាល់ខ្លួន។

**ប្រការ ៨.** ការរៀបចំជាក្រុម សម្រាប់ថ្នាក់សិក្សានីមួយៗ ត្រូវកំណត់ដោយសាកលវិទ្យាល័យ។

**ប្រការ ៩.** ការសុំប្តូរពេលសិក្សា (ព្រឹក-រសៀល-យប់) ត្រូវសម្រេចដោយគណៈគ្រប់គ្រងសាកលវិទ្យាល័យ។

## ផ្នែកទី ៣
## ការព្យួរការសិក្សា

**ប្រការ ១០.** និស្សិតអាចសុំព្យួរការសិក្សាបានរយៈពេលមួយឆ្នាំ និងអាចព្យួរបានតែ ២ដងគត់ក្នុងរយៈពេលសិក្សាតាមមុខជំនាញរបស់ខ្លួន។ ក្នុងអំឡុងពេលព្យួរការសិក្សា និស្សិតគ្មានសិទ្ធិប្រឡងឆមាស ឬឡើងថ្នាក់បានឡើយ។

**ប្រការ ១១.** ពេលសុំចូលរៀនវិញ និស្សិតត្រូវមកដាក់ពាក្យ និងបង់ថ្លៃសិក្សា ឲ្យបានមួយខែមុនពេលផុតកំណត់នៃរយៈពេលព្យួរការសិក្សា។ បើនិស្សិតរូបណាពុំបានមកដាក់ពាក្យសុំចូលរៀនតាមកាលកំណត់នេះទេ ត្រូវចាត់ទុកថា និស្សិតរូបនោះបានបោះបង់ចោលការសិក្សារបស់ខ្លួន។

## ផ្នែកទី ៤
## អំពីសីលធម៌

**ប្រការ ១២.** ក្នុងថ្នាក់រៀន

**ក.** និស្សិតត្រូវគោរពពេលវេលាតាមកាលវិភាគរបស់សាកលវិទ្យាល័យឲ្យបានម៉ឺងម៉ាត់។ ករណីមកយឺតលើសពី ១៥នាទី មិនអនុញ្ញាតឲ្យចូលរៀនឡើយ លើកលែងតែមានមូលហេតុត្រឹមត្រូវ ឬ មានការអនុញ្ញាតពីការិយាល័យសិក្សា។

**ខ.** និស្សិតត្រូវយកចិត្តទុកដាក់រៀនសូត្រ រក្សាសណ្តាប់ធ្នាប់ របៀបរៀបរយ និងមិនធ្វើអ្វី ដែលនាំឲ្យរំខានដល់មិត្តភក្តិរួមថ្នាក់ជាមួយ។

គ. ពេលលោកសាស្ត្រាចារ្យ ឬ ភ្ញៀវអញ្ជើញចូលក្នុងថ្នាក់រៀននិស្សិត ទាំងអស់ត្រូវក្រោកឈរ គោរពដោយរក្សាភាពស្ងៀមស្ងាត់ និង សម្តែងនូវអាកប្បកិរិយាថ្លៃថ្នូរ។

ឃ. ពេលលោកសាស្ត្រាចារ្យអវត្តមាន ឬ មកយឺតរយៈពេលលើសពី ១៥នាទី និស្សិតត្រូវរក្សាភាពស្ងៀមស្ងាត់ ហើយត្រូវចាត់តំណាង និស្សិតម្នាក់ឲ្យមកទំនាក់ទំនង និងទទួលព័ត៌មានពីការិយាល័យ សិក្សាផ្នែកកិច្ចការសាស្ត្រាចារ្យ។

ង. ពេលចេញលេង និស្សិតត្រូវប្រកាន់អាកប្បកិរិយាថ្លៃថ្នូរ ពោលគឺ មិនត្រូវប្រលែងគ្នា ស្រែកឡូឡា ឬ ឈ្លោះប្រកែកគ្នាឡើយ។

ច. ពេលចេញក្រៅថ្នាក់ ឬ ចេញទៅផ្ទះមុនម៉ោងដោយមានធុរៈចាំ បាច់ មានជំងឺផ្ទាល់ខ្លួន និស្សិតត្រូវសុំអនុញ្ញាតពីលោកសាស្ត្រាចារ្យ ដែលកំពុងបង្រៀន។

ឆ. និស្សិតមិនត្រូវនាំមិត្តភក្តិពីក្រៅ មកចូលក្នុងថ្នាក់របស់ខ្លួនឡើយ។

ជ. ហាមប្រើប្រាស់ទូរស័ព្ទដៃ ឬឧបករណ៍ទំនាក់ទំនងផ្សេងៗ ក្នុង ពេលកំពុងសិក្សា។

**ប្រការ ១៣.** ក្នុងបរិវេណសាកលវិទ្យាល័យ

ក. និស្សិតទាំងអស់មិនត្រូវ :

- ជក់បារី សេពគ្រឿងស្រវឹង និងប្រើប្រាស់ ឬ ជួញដូរគ្រឿងញៀន ឡើយ។
- យកអាវុធគ្រប់ប្រភេទ ជាតិផ្ទុះ គ្រឿងញៀន គ្រឿងស្រវឹង ឬ នាំ មិត្តភក្តិពីក្រៅចូលមកក្នុងបរិវេណសាកលវិទ្យាល័យឡើយ។
- លេងល្បែងស៊ីសង ឬ ប្រព្រឹត្តអំពើពាលា ដែលខុសពីប្រពៃណីជាតិ។

- ធ្វើសកម្មភាព ដែលនាំឲ្យប៉ះពាល់ដល់កិត្តិយស និងផលប្រយោជន៍របស់សាកលវិទ្យាល័យ និងសង្គមជាតិ។
- ស្រែកឡូឡា ឬ ប្រើពាក្យអាសអាភាស អាសគ្រាម និងអាកប្បកិរិយាមិនសមរម្យ ដែលប្រាសចាកអំពីទំនៀមទម្លាប់ខ្មែរ។
- ធ្វើឲ្យបាត់បង់សោភណភាព និងខូចបរិស្ថានដូចជា សរសេរគូសវាស លើជញ្ជាំង លើតុ ទ្វារ បង្អួចនៃបន្ទប់រៀន ចោលសម្រាម ឬ ស្ករកៅស៊ូ និងខាកស្តោះ លើជណ្តើរ លើកម្រាលឥដ្ឋ។ល។

**ខ.** រាល់បាតុភាពអសកម្ម ត្រូវរាយការណ៍មកការិយាល័យរដ្ឋបាល ឬ ភ្នាក់ងារសន្តិសុខជាបន្ទាន់ដូចជា:
- មានអគ្គីភ័យ
- និស្សិតមានជំងឺដែលត្រូវសង្គ្រោះជាបន្ទាន់
- និស្សិតឈ្លោះប្រកែក ឬ វាយតប់គ្នា
- មានអំពើចោរកម្ម
- មានសមាសភាព ឬ មុខសញ្ញាមិនល្អ គួរអោយសង្ស័យ។ល។

## ផ្នែកទី ៥
## អំពីការប្រឡង

**ប្រការ ១៤.** និស្សិតទាំងពីរភេទត្រូវមកប្រឡងឲ្យទាន់ពេលវេលា។ មិនអនុញ្ញាតឲ្យចូលប្រឡងក្នុងករណីដូចខាងក្រោម :
- មកយឺតលើសពី ១៥នាទី
- គ្មានអត្តសញ្ញាណប័ណ្ណ និងប័ណ្ណសម្គាល់ខ្លួន ឬ លិខិតបញ្ជាក់ពី

ការិយាល័យសិក្សា (ករណីភ្លេចអត្តសញ្ញាណប័ណ្ណ ឬ ប័ណ្ណសម្គាល់ខ្លួន)
- គ្មានបង្កាន់ដៃបង់ប្រាក់ (ចំពោះការប្រឡងសង)
- និស្សិតបង់ថ្លៃសិក្សាមិនទាន់គ្រប់ចំនួន
- គ្មានឯកសណ្ឋានដូចបានកំណត់ក្នុងប្រការ៤។

**ប្រការ ១៥.** នៅពេលប្រឡងនិស្សិតទាំងពីរភេទ ត្រូវគោរពតាមលក្ខខណ្ឌដូចខាងក្រោម៖
- អង្គុយតាមលេខតុ
- បំពេញក្បាលសន្លឹកកិច្ចការឲ្យបានគ្រប់ចំណុចតាមការណែនាំរបស់អនុរក្ស។ ករណីនិស្សិតមិនបានបំពេញក្បាលសន្លឹកកិច្ចការនោះត្រូវបានពិន្ទុសូន្យ។
- ចុះហត្ថលេខាលើបញ្ជីវត្តមានប្រឡង
- ប្រើប្រាស់ទឹកប៊ិចតែមួយពណ៌ ករណីផ្ទុយត្រូវមានការអនុញ្ញាតពីអនុរក្ស។
- រក្សាភាពស្ងៀមស្ងាត់ អង្គុយឲ្យបានសមរម្យ។
- ហាមងាកសួរអ្នកជិតខាង
- ហាមចេញក្រៅបន្ទប់ក្នុងពេលប្រឡង (លើកលែងតែមានការអនុញ្ញាតពិសេសពីអនុរក្ស)
- ហាមយកសំណៅឯកសារផ្សេងៗចូលក្នុងបន្ទប់ប្រឡងលើកលែងតែមានចែងក្នុងវិញ្ញាសាប្រឡង។
- ហាមប្រើទូរសព្ទដៃ និងឧបករណ៍អេឡិចត្រូនិចផ្សេងៗ ពាក់ព័ន្ធការ

លួចចម្លង។
- ត្រូវគោរព និងអនុវត្តតាមការណែនាំរបស់គណៈកម្មការត្រួតពិនិត្យ និងអនុរក្ស។
- នៅពេលចប់ម៉ោង និស្សិតត្រូវប្រគល់សន្លឹកកិច្ចការទៅឲ្យអនុរក្ស ទោះជាសន្លឹកកិច្ចការនោះគ្មានសរសេរចម្លើយក៏ដោយ។

## ជំពូកទី ៣
## វិធានការរដ្ឋបាលពាក់ព័ន្ធនឹងការសិក្សា

**ប្រការ ១៦.** និស្សិតដែលប្រព្រឹត្តផ្ទុយនឹងប្រការ ៣-៤-៥-៦-៧-៨-៩ ត្រូវទទួលវិធានការណ៍រដ្ឋបាលពីក្រុមប្រឹក្សាវិន័យនៃសាកលវិទ្យាល័យ។

**ប្រការ ១៧.** ករណីអវត្តមានឥតច្បាប់

**ក.** ការឈប់ឥតច្បាប់ចំនួនពី ៣ ទៅ ៦ដង ក្នុងមុខវិជ្ជាតែមួយនឹងត្រូវទទួលការព្រមានជាលើកទី ១ ដោយក្រុមប្រឹក្សាវិន័យ និងជូនដំណឹងដល់ឪពុកម្តាយ ឬអាណាព្យាបាល។

**ខ.** ការឈប់ឥតច្បាប់លើសពី ៦ដង ឡើងទៅក្នុងមុខវិជ្ជាតែមួយនឹងត្រូវទទួលការព្រមានជាលើកទី ២ ដោយក្រុមប្រឹក្សាវិន័យនឹងអញ្ជើញឪពុកម្តាយ ឬ អាណាព្យាបាលមកទទួលដំណឹងជាលើកចុងក្រោយ។

**គ.** ការឈប់ឥតច្បាប់ចំនួន ៣០% ឡើងទៅ ក្នុងមុខវិជ្ជាតែមួយត្រូវធ្លាក់លើមុខវិជ្ជានោះដោយស្វ័យប្រវត្តិ ហើយរង់ចាំប្រឡងសងឡើងវិញតាមការកំណត់កាលបរិច្ឆេទរបស់សាកលវិទ្យាល័យ។

**ឃ.** ការឈប់ឥតច្បាប់សរុបក្នុង ១ ឆមាស ចាប់ពី ៤០% ឡើងទៅត្រូវធ្លាក់ជាស្វ័យប្រវត្តិ។

**ប្រការ ១៨.** ករណីអវត្តមានមានច្បាប់

**ក.** និស្សិតត្រូវសុំច្បាប់ជាមុន នៅការិយាល័យសិក្សា ផ្នែកកិច្ចការនិស្សិត តាមរយៈប្រធានថ្នាក់ដោយបញ្ជាក់ពីមូលហេតុឲ្យបានច្បាស់លាស់។

**ខ.** នៅពេលប្រឡងនានា ដែលរៀបចំឡើងដោយសាកលវិទ្យាល័យ ការសុំច្បាប់ត្រូវធ្វើមុនថ្ងៃប្រឡងដោយភ្ជាប់សំណុំឯកសារ ដែលយកជាការបាន។ ករណីសុំច្បាប់ក្រោយថ្ងៃប្រឡងទុកជាអាសារបង់។

**គ.** ការឈប់មានច្បាប់ចំនួនពី ៣០% ឡើងទៅក្នុងមុខវិជ្ជាណាមួយ ការិយាល័យសិក្សា នឹងជូនដំណឹងដល់ឪពុកម្ដាយ ឬ អាណាព្យាបាល ព្រមទាំងកោះហៅនិស្សិតនោះមកទទួលដំណឹង។

**ឃ.** ការឈប់មានច្បាប់លើសពី ៤០% ក្នុងមុខវិជ្ជាណាមួយត្រូវកំណត់ថាធ្លាក់លើមុខវិជ្ជានោះដោយស្វ័យប្រវត្តិ ហើយត្រូវរង់ចាំការប្រឡងសងឡើងវិញ ដែលកំណត់កាលបរិច្ឆេទដោយសាកលវិទ្យាល័យ។

# ជំពូកទី ៤
# វិធានការរដ្ឋបាលពាក់ព័ន្ធពេលប្រឡង

**ប្រការ ១៩.** *ករណីមានកំហុសនៅពេលប្រឡង*

**ក.** *មានឯកសារ ឬសំណៅផ្សេងៗ បើកចម្លងនៅពេលប្រឡង :*

*- និស្សិតប្រព្រឹត្តខុសបទបញ្ជាប្រឡងលើកទី១ :*
*និស្សិតត្រូវចុះហត្ថលេខា ទទួលកំហុសលើកទី១។*

*- និស្សិតប្រព្រឹត្តខុសបទបញ្ជាប្រឡងលើកទី២ :*
*និស្សិតត្រូវចុះហត្ថលេខា ទទួលកំហុសលើកទី២ នឹងដកចំនួន ៥ពិន្ទុ។*

*- និស្សិតប្រព្រឹត្តខុសបទបញ្ជាប្រឡងលើកទី៣ :*
*និស្សិតត្រូវចុះហត្ថលេខា ទទួលកំហុសលើកទី៣ នឹងត្រូវបញ្ឈប់ការប្រឡងលើមុខវិជ្ជានោះ។*

**ខ.** *ដក ៥ពិន្ទុ ករណីអង្គុយខុសលេខតុរបស់ខ្លួន នឹងបញ្ឈប់ពីការប្រឡងក្នុងករណី មិនគោរពតាមការណែនាំរបស់អនុរក្ស។*

**គ.** *ត្រូវបានពិន្ទុសូន្យ ក្នុងករណីនិស្សិតបានប្រព្រឹត្តដូចខាងក្រោមនេះ :*

*- មិនបានប្រគល់សន្លឹកកិច្ចការ ដល់អនុរក្សនៅពេលបញ្ចប់ការប្រឡង។*

*- លួចមើលសំណៅឯកសារក្នុងបន្ទប់ទឹក ឬ ក្រៅបន្ទប់ប្រឡង។*

*- បោះសំណៅឯកសារទៅឲ្យមិត្តភក្តិ។*

**ប្រការ ២០.** ត្រូវបញ្ឈប់ពីការប្រឡងជាបន្ទាន់ និងបញ្ជូនទៅក្រុមប្រឹក្សាវិន័យដើម្បីវិនិច្ឆ័យករណីនិស្សិតដែលសម្តែងអាកប្បកិរិយាមិនសមរម្យប្រើពាក្យសំដីមិនថ្លៃថ្នូរស្រែកឡូឡា ដែលនាំឲ្យរំខានក្នុងពេលប្រឡង។

**ប្រការ ២១.** ករណីបង្កទំនាស់ជាមួយគណៈកម្មការប្រឡង ត្រូវទទួលពិន័យចាប់តាំងពីបញ្ឈប់ការប្រឡង រហូតដល់បណ្តេញចេញពីសាកលវិទ្យាល័យជាស្ថាពរ ដោយផ្អែកទៅលើទំហំនៃអំពើប្រព្រឹត្តជាក់ស្តែងដែលបានបង្កឡើង។

**ប្រការ ២២.** ករណីហែកចោលសន្លឹកកិច្ចការប្រឡង :

**ក.** បញ្ឈប់ពីការប្រឡងគ្រប់មុខវិជ្ជាទាំងអស់ក្នុងសម័យប្រឡងដែលកំពុងប្រព្រឹត្តទៅ។

**ខ.** អញ្ជើញឪពុកម្តាយ ឬ អាណាព្យាបាល មកទទួលដំណឹងផ្ទាល់ជាលើកចុងក្រោយ។

**គ.** ការប្រព្រឹត្តក្នុងករណីដដែលជាលើកទី២ទៀត ត្រូវលុបឈ្មោះចេញពីបញ្ជីនិស្សិតនៃសាកលវិទ្យាល័យជាស្ថាពរដោយគ្មានលក្ខខណ្ឌ។

**ប្រការ ២៣.** ក្នុងករណីមាននិស្សិតប្រឡងជំនួស ឬ ប្រឡងជួយនិស្សិតម្នាក់ទៀត និស្សិតទាំងពីររូបនេះ ត្រូវទទួលពិន័យពីក្រុមប្រឹក្សាវិន័យ ចាប់ពីបញ្ឈប់ការប្រឡងគ្រប់មុខវិជ្ជាទាំងអស់ក្នុងសម័យប្រឡង ដែលកំពុងប្រព្រឹត្តទៅរហូតដល់បណ្តេញចេញពីសាកលវិទ្យាល័យជាស្ថាពរដោយគ្មានលក្ខខណ្ឌ។

# ជំពូកទី ៥
# អំពីការវាយតម្លៃលទ្ធផលសិក្សា

**ប្រការ ២៤.** នៅក្នុងឆមាសនីមួយៗត្រូវមាន :

- ការប្រឡងត្រួតពិនិត្យ មួយដងយ៉ាងតិចក្នុងមុខវិជ្ជានីមួយៗ
- កិច្ចការស្រាវជ្រាវ (Assignment) មួយយ៉ាងតិចក្នុងមុខវិជ្ជានីមួយៗ
- ប្រឡងឆមាសមួយដងក្នុងមុខវិជ្ជានីមួយៗ ។

**ប្រការ ២៥.** រូបមន្តនៃការគណនាមធ្យមភាគតាមឆមាសនៃមុខវិជ្ជានីមួយៗគឺ :

១០% វត្តមាន វិន័យ សីលធម៌ និងសកម្មភាពសិក្សាក្នុងថ្នាក់
១៥% ការប្រឡងត្រួតពិនិត្យ
១៥% កិច្ចការស្រាវជ្រាវ (Assignment)
៦០% ការប្រឡងឆមាស

---

១០០% ពិន្ទុសរុបប្រចាំឆមាស

ចំពោះមុខវិជ្ជាណាមួយ ដែលមានពិន្ទុសរុបប្រចាំឆមាសក្រោម ៥០/១០០ ត្រូវចាត់ទុកថាធ្លាក់លើមុខវិជ្ជានោះ។

**ប្រការ ២៦.** សម្រាប់និស្សិតឆ្នាំទី ១, ២, ៣

**ក.** ក្នុងមួយឆ្នាំ មានការប្រឡងឆមាស ចំនួនពីរលើក (ឆមាសទី១, ឆមាសទី២) និងមុខវិជ្ជា ដែលជំពាក់ពីឆ្នាំសិក្សាមុន។

**ខ.** ករណីនិស្សិត ដែលមានពិន្ទុសរុបប្រចាំឆមាស ក្រោមមធ្យម ៥០/១០០ ឬ អវត្តមាននៅពេលប្រឡង (ឆមាសទី១, ទី២) ត្រូវ

បានអនុញ្ញាតឲ្យប្រឡងសងឡើងវិញតែម្តងគត់នៅដំណាច់ឆ្នាំសិក្សាតាមកាលបរិច្ឆេទកំណត់របស់សាកលវិទ្យាល័យ។ និស្សិតរូបណាអវត្តមាននៅពេលប្រឡង

គ. ពិន្ទុនៃការប្រឡងសងនេះ គឺមានតម្លៃ ៦០% នៃពិន្ទុសរុប ហើយយកទៅបូកជាមួយនឹងពិន្ទុ ៤០% នៃពិន្ទុវត្តមាន ពិន្ទុប្រឡងត្រួតពិនិត្យ និងពិន្ទុកិច្ចការស្រាវជ្រាវ ដែលបានធ្វើពីមុនមក ដើម្បីវាយតម្លៃលទ្ធផលលើមុខវិជ្ជានោះ។

ឃ. ពិន្ទុប្រឡងត្រួតពិនិត្យ និងពិន្ទុកិច្ចការស្រាវជ្រាវ លើមុខវិជ្ជានីមួយៗត្រូវបំពេញឲ្យបានចប់សព្វគ្រប់មុនសម័យប្រឡងឆមាស។ បើផ្ទុយពីករណីខាងលើត្រូវបានពិន្ទុសូន្យ។

ង. និស្សិតឆ្នាំទី១ (ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន) ត្រូវប្រឡងជាប់គ្រប់មុខវិជ្ជាទាំងអស់ក្នុងកម្មវិធីសិក្សា ទើបអាចទទួលវិញ្ញាបនបត្រថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន។

ច. ចំពោះនិស្សិតឆ្នាំទី២ ទី៣ និងទី៤ (ផ្នែកអគ្គិសនី និងអេឡិចត្រូនិច, ផ្នែកសំណង់ស៊ីវិល, ផ្នែកស្ថាបត្យកម្ម) ដែលប្រឡងសងរួចហើយ ហើយនៅបានពិន្ទុសរុបក្រោមមធ្យម (៥០/១០០) ចាប់ពីពីរមុខវិជ្ជាឡើងទៅត្រូវរៀនត្រួតថ្នាក់ (ពីរកម្រិតនៃមុខវិជ្ជាតែមួយគិតពីរមុខវិជ្ជា)។ ត្រូវបានឡើងថ្នាក់ ចំពោះនិស្សិតទាំងឡាយណាដែលបានប្រឡងជាប់គ្រប់មុខវិជ្ជាទាំងអស់ ឬ ធ្លាក់តែមួយមុខវិជ្ជាប៉ុណ្ណោះ។

ឆ. មុខវិជ្ជាដែលជំពាក់ ត្រូវប្រឡងសងឡើងវិញនៅឆ្នាំសិក្សាបន្ទាប់តាមកាលបរិច្ឆេទកំណត់របស់សាកលវិទ្យាល័យក្នុងតម្លៃ ១០ដុល្លារ។

**ប្រការ ២៧.** សម្រាប់និស្សិតឆ្នាំសិក្សាបញ្ចប់

**ក.** និស្សិតត្រូវប្រឡងសងលើមុខវិជ្ជាដែលជំពាក់នៅឆ្នាំសិក្សាចាស់ឲ្យជាប់ជាស្ថាពរទើបអនុញ្ញាតឲ្យចូលប្រឡងឆមាសទី១ ដោយត្រូវបង់តម្លៃ ១០ដុល្លារ។

- ក្រោយប្រឡងឆមាសទី១ ហើយមានមុខវិជ្ជាធ្លាក់ត្រូវប្រឡងសងតាមកាលបរិច្ឆេទកំណត់របស់សាកលវិទ្យាល័យ (ប្រឡងសងលើកទី១)។
- ប្រសិនបើនៅមានធ្លាក់ទៀត ត្រូវប្រឡងសងម្តងទៀត(ប្រឡងសងលើកចុងក្រោយ) តាមកាលបរិច្ឆេទកំណត់ របស់សាកលវិទ្យាល័យ។

**ខ.** ក្នុងករណីធ្លាក់តែមួយមុខវិជ្ជាក្រោយការប្រឡងសងលើកចុងក្រោយនិស្សិតនោះ ត្រូវបានអនុញ្ញាត ឬ មិនអនុញ្ញាតឲ្យប្រឡងបញ្ចប់ថ្នាក់បរិញ្ញាបត្រ (State Exam) តាមសេចក្តីសម្រេចរបស់គណៈកម្មការប្រកាសលទ្ធផល។

**គ.** ក្នុងករណីធ្លាក់ចាប់ពី២មុខវិជ្ជាឡើងទៅក្រោយការប្រឡងសងលើកចុងក្រោយ មិនអនុញ្ញាតឲ្យប្រឡងបញ្ចប់ថ្នាក់បរិញ្ញាបត្រឡើយ។ និស្សិតត្រូវរៀនមុខវិជ្ជា ដែលធ្លាក់នៅឆ្នាំក្រោយ ហើយត្រូវបង់ថ្លៃសិក្សាទៅតាមចំនួនមុខវិជ្ជា ដែលធ្លាក់ដោយគិតជាតម្លៃក្នុង១មុខវិជ្ជា ៤០ដុល្លារ។ និស្សិតរូបនេះត្រូវបន្តចូលរួមការសរសេរសារណារបស់ខ្លួនជាមួយក្រុមដដែលរហូតចប់សព្វគ្រប់ជាស្ថាពរ ដើម្បីប្រើប្រាស់សារណានោះ សម្រាប់ការពារនៅឆ្នាំក្រោយលើកលែងតែនិស្សិតផ្នែកសំណង់ ស្ថាបត្យកម្ម វិស្វកម្មអគ្គិសនី។

**ឃ.** ចំពោះនិស្សិតដែលប្រឡងបញ្ចប់ថ្នាក់បរិញ្ញាបត្រ (State Exam) ធ្លាក់ និស្សិតរូបនេះ ត្រូវរង់ចាំប្រឡងបញ្ចប់ថ្នាក់បរិញ្ញាបត្រ (State Exam) លើកទី២ នៅរយៈពេលពីរសប្តាហ៍ក្រោយប្រកាសលទ្ធផល ដោយត្រូវបង់តម្លៃ ១០ដុល្លារ សម្រាប់ចូលប្រឡង។ ករណីធ្លាក់ទៀត ត្រូវរង់ចាំប្រឡងនៅឆ្នាំបន្ទាប់ រហូតបានលទ្ធផលជាប់ជាស្ថាពរទើបអនុញ្ញាតឲ្យចូលការពារសារណាដើម្បីបញ្ចប់យកបរិញ្ញាបត្រដោយត្រូវបង់តម្លៃ ៣០ដុល្លារ ដើម្បីសុំចុះឈ្មោះ និងសុំសិទ្ធិប្រឡងនៅឆ្នាំក្រោយ។

**ង.** ចំពោះនិស្សិត ដែលធ្លាក់ផ្នែកសារណា ត្រូវរង់ចាំការការពារឡើងវិញនៅឆ្នាំក្រោយ។ និស្សិតរូបនេះ ត្រូវបង់តម្លៃ ៣០ដុល្លារ ដើម្បីសុំចុះឈ្មោះ និង សុំសិទ្ធិការពារសារណានៅឆ្នាំក្រោយ។

**ច.** ការកំណត់ពិន្ទុនៃការប្រឡងបញ្ចប់ថ្នាក់បរិញ្ញាបត្រ (State Exam) យកតែមុខវិជ្ជាជំនាញ ដែលកំណត់ដោយសាកលវិទ្យាល័យហើយលទ្ធផលជាប់ លុះត្រាតែមុខវិជ្ជានីមួយៗ មានពិន្ទុចាប់ពី ៥០% ឡើងទៅ។ មុខវិជ្ជាណាដែលមានពិន្ទុតិចជាង ៥០% ត្រូវធ្វើការប្រឡងមុខវិជ្ជានោះឡើងវិញក្នុងការប្រឡងបញ្ចប់លើកទី២។

**ឆ.** ការកំណត់ពិន្ទុសារណាត្រូវបានបែងចែកជាបីផ្នែក :
- ការប្រឹងប្រែងចូលរួម (ដាក់ពិន្ទុដោយសាស្ត្រាចារ្យណែនាំ) ១០%
- ការសរសេរសារណា (ដាក់ពិន្ទុដោយគណៈកម្មការ) ៤០%
- ការការពារសារណា (ដាក់ពិន្ទុដោយគណៈកម្មការ) ៥០%

លទ្ធផលជាប់លុះត្រាតែទទួលបានពិន្ទុសរុបចាប់ពី ៦០% ឡើងទៅ។

**ជ.** ត្រូវបានកំណត់ថា បានបញ្ចប់កម្រិតបរិញ្ញាបត្រលុះត្រាតែនិស្សិត

បានបំពេញគ្រប់លក្ខខណ្ឌដូចខាងក្រោម :

- បានប្រឡងជាប់លើគ្រប់មុខវិជ្ជា ដែលបានសិក្សាទាំងអស់
- បានប្រឡងជាប់ការប្រឡងបញ្ចប់ថ្នាក់បរិញ្ញាបត្រ (State Exam)
- បានអនុវត្តគម្រោងស្រាវជ្រាវ និងការពារសារណា ឬ បានប្រតិបត្តិកម្មវិធីអនុវត្តដោយជោគជ័យ។
- បានឆ្លងកាត់ការអនុវត្តជាក់ស្តែងយ៉ាងតិច ១០០ ម៉ោង។

**ឈ.**ការកំណត់និទ្ទេសត្រូវកំណត់ដូចខាងក្រោម :

$$\text{ពិន្ទុ} = \frac{\text{មធ្យមភាគនៃមុខវិជ្ជាទាំងអស់} + \text{ពិន្ទុ State Exam} + \text{ពិន្ទុសារណា}}{៣}$$

| | | | | |
|---|---|---|---|---|
| Grade A | : | 85 → 100 | ល្អវិសេសវិសាល | Excellent |
| Grade B+ | : | 80 → 84+ | ល្អណាស់ | Very good |
| Grade B | : | 70 → 79+ | ល្អ | Good |
| Grade C+ | : | 65 → 69+ | ល្អបង្គួរ | Fairly Good |
| Grade C | : | 50 → 64+ | មធ្យម | Fair |
| Grade D | : | 0 → 49+ | ធ្លាក់ | Fail |

## ជំពូកទី ៦
## អំពីសិល្បៈ និង កីឡា

**ប្រការ ២៨.** *អំពីសិល្បៈ*

*និស្សិតទាំងពីរភេទ អាចចូលរួមក្នុងសកម្មភាពសិល្បៈវប្បធម៌ ដែលរៀបចំឡើងដោយសាកលវិទ្យាល័យ ដើម្បីចូលរួមចំណែកលើកស្ទួយ និងការពារសិល្បៈវប្បធម៌ប្រពៃណីខ្មែរ។*

**ប្រការ ២៩.** *អំពីកីឡា :*

*និស្សិតទាំងពីរភេទ អាចចូលរួមក្នុងសកម្មភាពកីឡា ដែលរៀបចំដោយសាកលវិទ្យាល័យ និងអាចចូលរួមក្នុងការប្រកួតប្រជែងជម្រើសជើងឯកប្រចាំសាកលវិទ្យាល័យ និងថ្នាក់ជាតិ។*

## ជំពូកទី ៧
## ការចូលរួមក្នុងកម្មវិធីផ្សេងៗ

**ប្រការ ៣០.** *និស្សិតត្រូវចូលរួមក្នុងកម្មវិធីផ្សេងៗ ដែលរៀបចំដោយសាកលវិទ្យាល័យដូចជាពិធី :*

- *តាំងពិព័រណ៍ប្រចាំឆ្នាំ*
- *ទស្សនកិច្ចសិក្សា*
- *សិក្ខាសាលា*
- *សំណេះសំណាលជាមួយមន្ត្រីជាន់ខ្ពស់នៃរាជរដ្ឋាភិបាល ថ្នាក់ដឹកនាំ*

ក្រុមហ៊ុនអង្គការជាតិ និងអន្តរជាតិ
- ប្រជុំផ្សព្វផ្សាយផែនការផ្សេងៗ
- ចែករង្វាន់លើកទឹកចិត្តដល់និស្សិតថ្មើម
- ពិធីចែកសញ្ញាបត្រ ...

**ប្រការ ៣១.** រាល់ពិធីនានាដែលរៀបចំដោយនិស្សិតនៅក្នុងសាកលវិទ្យាល័យត្រូវមានការអនុញ្ញាតជាមុនពីគណៈគ្រប់គ្រងសាកលវិទ្យាល័យ។

## ជំពូកទី ៨
## ការចូលរួមពិធីប្រគល់សញ្ញាបត្រផ្លូវការ

**ប្រការ ៣២.** និស្សិតត្រូវមានវត្តមានចាំបាច់ ក្នុងពិធីប្រគល់សញ្ញាបត្រ និងត្រូវបំពេញគ្រប់លក្ខខណ្ឌ និងគោលការណ៍ទាំងអស់ ដែលតម្រូវដោយសាកលវិទ្យាល័យមាន ជាអាទិ៍ : តម្លៃសេវារៀបចំឯកសារ និងថ្លៃជួលឯកសណ្ឋាន។ល។

**ប្រការ ៣៣.** ក. និស្សិតអវត្តមានដោយករណីណាមួយនៅក្នុងពិធីប្រគល់សញ្ញាបត្រចាំបាច់ត្រូវបំពេញគ្រប់លក្ខខណ្ឌ និងគោលការណ៍ទាំងអស់ដែលតម្រូវ ដោយសាកលវិទ្យាល័យ ដូចនិស្សិតដែលមានវត្តមានក្នុងពិធីប្រគល់សញ្ញាបត្រជាផ្លូវការដែរ ដើម្បីអាចសុំដកយកសញ្ញា-បត្ររបស់ខ្លួនបាន។

ខ. និស្សិតអវត្តមានក្នុងពិធីប្រគល់សញ្ញាបត្រជាផ្លូវការ អាចសុំដកសញ្ញាបត្ររបស់ខ្លួនបាននៅការិយាល័យសិក្សារយៈពេល១ សប្តាហ៍

ក្រោយពេលប្រារព្ធពិធី បន្ទាប់ពីបានអនុវត្តត្រឹមត្រូវដូចមានចែង ក្នុងប្រការ៣២។

## ជំពូកទី ៩
## អំពីសក់ក្បាល

**ប្រការ ៣៤.** និស្សិតទាំងពីរភេទត្រូវកាត់សក់ ឬ តុបតែងសក់ ឲ្យមានភាពសមរម្យ និង ថ្លៃថ្នូរ។

ក. និស្សិតប្រុសត្រូវកាត់សក់ខ្លីសមរម្យ និងមានសណ្តាប់ធ្នាប់ល្អ

ខ. និស្សិតប្រុស និងស្រីមិនត្រូវលាបពណ៌សក់បង្ហាញនូវភាពសិចស៊ីឡើយ

គ. ករណីប្រព្រឹត្តផ្ទុយពីការណែនាំខាងលើ នឹងមិនត្រូវបានអនុញ្ញាតឲ្យ ចូលក្នុងបរិវេណសាកលវិទ្យាល័យឡើយ។

## ជំពូកទី ១០
## អំពីសេវាសុខភាព

**ប្រការ ៣៥.** ក. ក្នុងបរិវេណសាកលវិទ្យាល័យនិស្សិតដែលមានជំងឺអាចមកពិគ្រោះ និងព្យាបាលជំងឺ នៅគិលានដ្ឋានរបស់សាកលវិទ្យាល័យ ដើម្បីសង្គ្រោះបឋម។ បើករណីធ្ងន់ធ្ងរត្រូវបញ្ជូនទៅមន្ទីរពេទ្យ។

ខ. និស្សិតដែលមានជំងឺធ្ងន់ ឬ ជំងឺធ្ងន់ធ្ងរជាប្រចាំ ត្រូវបានអនុញ្ញាតច្បាប់ ឈប់សម្រាកតាមវេជ្ជបញ្ជា ឬ ការណែនាំរបស់គ្រូពេទ្យ។

# ជំពូកទី ១១
# វិធានការរដ្ឋបាល និងការលើកទឹកចិត្ត

**ប្រការ ៣៦.** កម្រិតនៃវិធានការរដ្ឋបាលចំពោះនិស្សិតដែលមានកំហុស :
- ការស្តីបន្ទោសដោយផ្ទាល់មាត់ ឬ ជាលាយលក្ខណ៍អក្សរ
- បិទប្រកាសផ្សាយជាសាធារណៈនៅក្នុងបរិវេណសាកលវិទ្យាល័យ
-ឲ្យបង់សំណងជាប្រាក់ទៅតាមទំហំ នៃការខូចខាតសម្ភារៈ របស់សាកលវិទ្យាល័យ
- ចារឹកក្នុងសៀវភៅឯកសារវាយតម្លៃរបស់និស្សិត នៃសាកលវិទ្យាល័យ
- ព្យួរការសិក្សា
- បញ្ឈប់ការសិក្សាជាស្ថាពរពីសាកលវិទ្យាល័យ ដោយគ្មានលក្ខខណ្ឌ។

**ប្រការ ៣៧.** អំពីការលើកទឹកចិត្ត :
- ដោយតាំងរូបថតនៅលើតារាងកិត្តិយស និងផ្សាយតាមព្រឹត្តិប័ត្ររបស់សាកលវិទ្យាល័យ
- ដោយជូនលិខិត ឬ ប័ណ្ណសរសើរ
- ដោយជូនរង្វាន់
- ដោយចារឹកនៅក្នុងសៀវភៅឯកសារវាយតម្លៃរបស់និស្សិត

# ជំពូកទី ១២
# អវសានបញ្ញត្តិ

**ប្រការ ៣៨.** និស្សិត-សាស្ត្រាចារ្យ ក្រុមប្រឹក្សាវិន័យ ការិយាល័យរដ្ឋបាល និង បុគ្គលិកការិយាល័យសិក្សា ការិយាល័យបច្ចេកទេស និងស្រាវជ្រាវ ការិយាល័យគណនេយ្យ ត្រូវអនុវត្តបទបញ្ជានេះតាមភារកិច្ចរៀងៗខ្លួន ឲ្យមានប្រសិទ្ធភាពខ្ពស់បំផុត។

**ប្រការ ៣៩.** រាល់បទបញ្ជាទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីបទបញ្ជានេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៤០.** សេចក្ដីសម្រេចនេះ មានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ភ្នំពេញ, ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ ២០២៤

**សាកលវិទ្យាធិការ**

**ចាន់ សុខឃាង**

កន្លែងទទួល :
- ក្រសួងអប់រំយុវជន និង កីឡា
"ដើម្បីជូនជ្រាប"
- នាយកដ្ឋានឧត្តមសិក្សា
"ដើម្បីជូនជ្រាប"
- ដូចប្រការ ៣៦ "ដើម្បីអនុវត្ត"
- ឯកសារ
- កាលប្បវត្តិ

**KINGDOM OF CAMBODIA**

**Nation Religion King**

**Norton University**

**No: ________**

# INTERNAL REGULATIONS

# FOR

# NORTON UNIVERSITY UNDERGRADUATES

The Rector of Norton University, in reference to

- sub-decree No. 51 dated 18 September 1997 on the establishment of Norton University by Mr. Chan Sok Khieng, the Rector,
- sub-decree No. 46 dated 25 July 2002 on restructuring Norton College to Norton University,
- the internal regulations for undergraduate students dated 06 October 2003, and
- the imperative need of Norton University,

approves the following:

## Chapter I

## Regulation on Enrolment

**Section 1** Admission

A. Enrolment of year I (Foundation Studies) shall be made only when students have High School

Certificate (GCE) or any equivalent certificate /document.

B. Graduate students shall have a bachelor's degree or any equivalent degree.

C. Students holding degrees or any other certificates from any other Educational Institutions and wish to pursue their studies at Norton University shall go through an evaluation process conducted by the University Academic Board.

**Section 2** All students shall pay the school fees before the next academic year starts and the money paid is non-refundable.

## Chapter II

## Disciplines

### Part 1: Uniform

**Section 3** All students except evening students should wear the uniform prescribed by the University: a shirt tucked in the trousers or in a skirt (Sampot).

A. Male students should wear dark blue trousers, a sky-blue shirt, and shoes. Flip-flops are not allowed.

B. Female students should wear dark blue skirts, sky blue blouses, and sandals.

C. Evening students should dress properly:

- Tuck their shirt in trousers or in a skirt (except a shirt with three pockets)
- T-shirt is not allowed
- Shorts are not allowed.

D. Students of all shifts are not allowed to wear flip flops in university campus.

**Section 4** When taking an examination, defending a thesis or participating in any event of the University, all students shall wear the uniform as prescribed in section 3 above with a plain blue tie prescribed by the University.

**Section 5** All shifts student in morning, afternoon and evening sessions must wear their ID cards all times when they enter or leave the class and campus.

## Part 2: Academic Affairs

**Section 6** Students shall study in conformity with the schedule and program set by the University.

**Section 7** Students shall be allowed to apply for any faculties in the University in year II when they successfully complete and pass their year I (Foundation Studies).

**Section 8** The arrangement of groups for each class shall be the responsibility of the University.

**Section 9** All students shall seek an approval from the University if attempt to change the shift.

## Part 3: Suspension of Studies

**Section 10** Students can be allowed to suspend their studies for up to 2 time / 2 year at most depend on each program duration. During the suspension, students shall not be allowed to take tests or examinations.

**Section 11** To resume their studies, students shall submit the Application form and shall pay the school fees at least one month before the suspension period ends; otherwise, s/he will be considered as a drop-out.

## Part 4: Code of Conduct

**Section 12** In their classes,

A. All students shall fully observe punctuality based on the time schedule set by the University. If more than 15 minutes late, the students shall not be allowed to enter the classroom until an acceptable reason or a notice of approval from Registrar's Office is presented.
B. Students shall pay full attention to their studies, shall maintain order inside and outside the classroom, and shall not do anything that disturbs their classmates.
C. When a lecturer or guest enters the room, students shall keep quiet and show good manners and dignity.
D. If the lecturer is absent or is more than 15 minutes late, students shall maintain silence and shall send a representative to contact the Office of Lecturer Affairs for information.
E. During the break-time, students shall behave properly, shall not romp around or make loud noise or provoke quarrel.
F. Students shall ask their respective class lecturer for permission if they wish to go out or leave early due to some personal reasons or some emergency.

G. Students shall not be allowed to bring to the University campus anybody who does not belong to the University during class.
H. Students shall not be allowed to use mobile phones or any communication device during class.

**Section 13** On the University Campus,

A. Students shall not
- smoke, drink alcohol, or use/trade prohibited drugs.
- bring in weapons, explosives, prohibited drugs, alcohol, or anybody who does not belong to the University.
- gamble or commit immoral acts.
- Commit any activity that negatively affects the prestige of the University and the society.
- make noise or use any obscene / insulting words which are considered objectionable to Cambodian tradition.
- pollute the environment of the University such as writing graffiti on walls, tables, doors, windows, littering anywhere, or spitting on stairs, floors, etc.

B. Students shall immediately inform the Office of Administration and Personnel or security staff about the following cases:
  - fire
  - need of first aid assistance
  - argument or fighting
  - theft
  - any harmful actions or suspects, and so on.

## Part 5: Examination

**Section 14** Students shall come to the examination room on time. They shall not be allowed to sit for the examination due to the following reasons:

- More than 15 minutes late
- No student ID card or any certification from the Registrar's Office (in case they do not bring with them ID card)
- No tuition fee receipt (supplementary exam)
- Failing to pay the complete tuition fee.
- Not wearing the University uniform as mentioned in section 4

**Section 15** Students are expected to abide by the following conditions:

- Sit in the right seat
- Fill out completely the examination papers's letterhead directed by any invigilator. If the students have not filled out the letterhead, they are given zero mark.
- Sign on the exam attendance sheet.
- Use as one-color pen, if need to change the pen, the student shall ask for permission from the invigilator.
- Keep silent and be properly seated.
- Do not ask other candidates.
- Do not go outside the examination room (unless permitted by the invigilator).
- Do not bring in the examination room any crib sheet unless permitted by the Examination Committee.

- Do not use any mobile phone or electronic tools in terms of cheating/copying during the examination.
- Follow the guidelines of the examination controller(s) and invigilator.
- At the end of the examination period every student shall submit her / his exam paper to the proctor even though the paper is blank in order to get their student ID cards.

## Chapter III

## Punishments during the performance

**Section 16** The students who violate sections 3-4-5-6-7-8 and 9 shall be punished by the University Discipline Committee.

**Section 17** Leave without permission

A. Those who are absent three to six times on one subject without permission shall be given the first warning; the Discipline Committee will inform their parents or guardians about this matter.
B. Those who are absent more than six times on one subject without permission shall be given the second warning and their parents or guardians will be invited to the Discipline Committee.
C. Those who are absent 30% up on one subject shall automatically fail that subject and shall do the supplementary examination as approved by the University.
D. Those who are absent 40% up in one semester shall automatically fail.

**Section 18** Leave of Absence

A. The students shall ask permission in advance from the registrar's office, in the student affairs room, through their class monitor with acceptable reasons.
B. The students shall ask for leave of absence with reasonable papers before the exam date set by the University or it will be considered invalid if late.
C. Having 30% of leaves of absence or more on one subject, the student shall be warned and their parents or guardians shall be informed.
D. Having 40% of leaves of absence or more on one subject, the student shall fail that subject and shall do the supplementary examination approved by the University.

## Chapter IV

## Punishments during the examination

**Section 19** Cheating on Examination

A. If caught copying from a forbidden source;
   - The first time, the student must sign the warning column on the attendance sheet
   - The second time, the student must sign for cheating and five marks will be deducted from their score.
   - The third time, the student will sign to acknowledge their cheating and be dismissed from the examination room for that subject.
B. If sitting in the wrong seat, five marks shall be deducted and if not following the instruction of the

proctor, the student shall be dismissed from the examination room.

C. The student shall be given zero mark for the particular subject:
   - If not returning the examination paper to the proctor.
   - Cheating on examination tasks in the bathroom or outside the exam room.
   - Send examination tasks to friend.

D. If not returning the examination paper to the proctor, the student shall be given zero mark for the particular subject.

**Section 20** If behaving improperly, using improper language, and making disturbing noise, the student shall be promptly stopped doing an examination and be sent to the Discipline Committee.

**Section 21** If making a quarrel with any member of the Examination Committee, the student shall be dismissed from the examination room or dismissed from the University based on the seriousness of the commitment.

**Section 22** If found tearing the examination paper:

A. The student shall be dismissed from the examination room for all subjects.

B. The student's parents or guardians shall be invited to the University and be finally informed about the matter.

C. If tears the examination paper at the second time, the student shall be dismissed from the University.

**Section 23** Both the substitute student and the helping student during the examination shall be dismissed from the examination room for all subjects being done and dismissed from the University by the Examination Committee.

## Chapter V

## Academic Evaluation

**Section 24** In each semester there is:

- At least one revision test in each subject
- At least one assignment in each subject, and
- One semester examination in each subject.

**Section 25** The following is the grading system:

| | |
|---|---|
| • Attendance, discipline, morality and participation | 10% |
| • Revision test(s) | 15% |
| • Assignments and Homework | 15% |
| • Semester examination | 60% |
| **Total scores** | **100%** |

Any students whose scores are under 50% in a subject is considered failed in that subject.

**Section 26** For year I-II-III Students

A. There are two semester examinations a year and the exam of the subject failed in the previous year.

B. Those whose total scores are under 50% and those who were absent on the examination day(s) (first and / or second semester examination) shall be

allowed to take the only one supplementary examination once only at the end of the academic year as approved by the University. Any students fail to sit this supplementary shall be automatically given zero mark.

C. The total scores are the constitution of the 60% from the supplementary examination and 40% from the ongoing assessment.
D. Ongoing assessment scores of each course must be completed before the examination. Otherwise, the student will get zero mark.
E. Students will be provided the Certificate of Foundation Year and allowed to sit in year II only they have completed and passed all the subjects in year I.
F. Year II, III, and IV students (Faculties: Electronic and Electricity, Civil Engineering, and Architecture) who get less than 50% of the total marks from 2 subjects up, or (two levels in one subject is considered as two subjects) will have to repeat the year.
G. The students shall do the supplementary examination for the subjects they failed the following year as the schedule with payment of 10$ per subject.

**Section 27** For year IV students

A. Only those whose pass all the subjects (in year I, II, and III) are allowed to do the first semester examination as approved by the University.

- If failed any subject, the student shall take the first supplementary examination as approved by the University.
- If failed the same subject again, the student shall take the second (final) supplementary examination as approved by the University.

B. If failed one subject after the last supplementary examination, the student can either be allowed or not allowed to take the state examination depending on the decision of the University Board.

C. If failed two subjects after the last supplementary examination, the student is not allowed to take the state examination. He or she shall study the failed subjects the following academic year and pay $40 per failed subject. However, this student is allowed to continue to do his or her thesis in the same assigned group till the end of the process.

D. If failed the state examination, the student is allowed to do a supplementary state examination result is announced. If s/he fails again, the student must do another supplementary state examination the following academic year and must pay $30 to be registered. If he/she passes, he/she is allowed to defend his or her thesis.

E. Those who failed the thesis defense are allowed to do it again the following year, but shall pay 30$ to be registered.

F. Only the core subjects that are approved by the University are marked for the state examination. The total scores are 100%.

G. 40% of the total scores are given to the written work and 60% to the oral defense.

H. Only those who passed all the learned subjects, state examination, and thesis are given the degree.

I. Grading system is shown below:

$$\textbf{Total scores} = \frac{\textbf{Average score of all subjects + score of state exam + score of thesis}}{\textbf{3}}$$

| | | | | |
|---|---|---|---|---|
| Grade A | : 85 | → | 100 | Excellent |
| Grade B$^+$ | : 80 | → | 84$^+$ | Very good |
| Grade B | : 70 | → | 79$^+$ | Good |
| Grade C$^+$ | : 65 | → | 69$^+$ | Fairly good |
| Grade C | : 50 | → | 64$^+$ | Fair |
| Grade D | : 0 | → | 49$^+$ | Fail |

## Chapter VI
## Arts and Sports

**Section 28** About Art

All students shall be allowed to participate in any cultural, art show organized by the University in order to uphold and preserve Khmer cultural arts.

**Section 29** About Sport

All students shall be allowed to participate and compete in any sports activities / championship games organized by the University or at national level.

## Chapter VII
## Participating in University Activities

**Section 30** Students shall participate in any activities organized by the University such as:

- Annual education fairs
- Study tour
- Workshops
- Cordial chat with high-ranking government official, leaders of companies, local / international NGOs.
- Meeting and disseminating plans
- Awarding ceremony for the outstanding students

**Section 31** To organize any events on the University campus the students shall ask for permission from the University.

## Chapter VIII
## Attendance at the graduation ceremony or Commencement Exercises

**Section 32**. Students must be present at the graduation ceremony and must complete all conditions and principles required by the university, including: fees, document preparation services and uniform rental days, etc.

**Section 33.** A. Students absent in any occasion at graduation ceremony, it is necessary to complete all the conditions and principles required by the university as well as the students who are present at the official graduation ceremony to be able to apply for their certificates.

Students who are absent from the official graduation ceremony may request to withdraw their certificates at the academic office after following the application as stated on Section 32 one week after the ceremony.

## Chapter IX
## About Hair

**Section 34.** All students must cut their hair or decorate their hair appropriately and with dignity

A. Male students must cut their hair short, decent and in good order
B. All students do not have to dye their hair to show their sexiness
C. In case do opposite of all above guidelines will not be allowed in university campus.

## Chapter X
## Health Service

**Section 35** A. Students who have health problems within the University campus shall come and see the doctor at the University clinic for first aid treatment. In case of serious health problems, students shall be taken to the hospital.

B. Those with highly infectious diseases or serious chronic disease shall inform the University.

## Chapter XI
## Administrative Actions and Motivation

**Section 36** The following are the administrative actions for offending students:

- Giving verbal or written warnings
- Posting written warning on the University Campus
- Compensating the damage based on the seriousness of the damage
- Recording in the student academic book
- Suspending from the University
- Dismissing from the University

**Section 37** Students shall be motivated by the following means:

- Posting their photographs on the honorary roll or publishing their names and photographs in the University annual bulletin / newsletter
- Presenting certificates of appreciation
- Presenting rewards
- Recording in the student academic book

## Chapter X
## The Final Provisions

**Section 38** Students, lecturers, the Discipline Committee, the Office of Administration and Personnel, the Office of Academic and Research, the Accounts Office, shall hereafter effectively implement these regulations with respect to their assigned duties and responsibilities.

**Section 39** Any regulation contrary to these regulations shall be considered null and void.

**Section 40** This decision shall take its effects from the date of the signing hereafter.

**February 29, 2024**



........................

**Chan Sok Khieng**

Rector

**CC.**

- Ministry of Education, Youth, and Sports
- Department of Higher Education
- Documentation Committee

..........................................................................................................................................................................................
..........................................................................................................................................................................................
..........................................................................................................................................................................................
..........................................................................................................................................................................................
..........................................................................................................................................................................................
..........................................................................................................................................................................................
..........................................................................................................................................................................................
..........................................................................................................................................................................................
..........................................................................................................................................................................................
..........................................................................................................................................................................................
..........................................................................................................................................................................................
..........................................................................................................................................................................................
..........................................................................................................................................................................................
..........................................................................................................................................................................................
..........................................................................................................................................................................................
..........................................................................................................................................................................................
..........................................................................................................................................................................................
..........................................................................................................................................................................................
..........................................................................................................................................................................................
..........................................................................................................................................................................................
..........................................................................................................................................................................................
..........................................................................................................................................................................................

ការចាប់ផ្តើមជីវិតថ្មី

A new life started

អគារសាកលវិទ្យាល័យន័រតុន




បង្គុំនៃរចនាបថបុរាណខ្មែរ
ប្រាសាទព្រះវិហារ
និងប្រាសាទអង្គរវត្ត

Value Time
and Quality
by
developing a spirit of
academic inquiry
at

**NORTON UNIVERSITY .**

Be Assured Of
Your Future...

**Quality**

**Intellectual Capital**



Our Mascot

អាសយដ្ឋាន : សាកលវិទ្យាល័យន័រតុន ផ្លូវកែវចិន្តា សង្កាត់ជ្រោយចង្វា ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

ទូរសព្ទ : ០២៣ ៤៣២ ០៧៥ ទូរសព្ទដៃ : ០៩៣ ៨៨៨ ៥៦៩ / ០៩៣ ៨៨៨ ៣៥៩

E-mail : info@norton-u.com www.norton-u.com

© 2024